**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៣៥៧ សហវ.

# ប្រកាស

## ស្តីពីការអនុវត្តន៍អាករលើតម្លៃបន្ថែមចំពោះ ឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យា ដែលធ្វើការផ្គត់ផ្គង់ផលិតផលឬសេវា សម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស_៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៩ ដែលបានធ្វើវិសោធនកម្មដោយអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១
- យោងសេចក្តីជូនដំណឹងលេខ ៦៨០ សជណ. ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០០៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច :

**ប្រការ ១ .-**

ឧស្សាហកម្មគាំទ្រ ឬ អ្នកចុះកិច្ចសន្យា ដែលធ្វើការផ្គត់ផ្គង់ផលិតផលឬសេវាដោយផ្ទាល់សម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង ត្រូវបានទទួលការអនុគ្រោះមួយចំនួនពីការអនុវត្តន៍អាករលើតម្លៃបន្ថែម ។

សម្រាប់គោលដៅនៃប្រកាសនេះ :

១. ពាក្យ " ឧស្សាហកម្មគាំទ្រ" សំដៅដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងមាត្រា២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើការនាំចេញដោយផ្ទាល់ ឬដែលបានធ្វើការផ្គត់ផ្គង់ដោយផ្ទាល់នូវ ផលិតផល ឬសេវា របស់ខ្លួន សម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង ។

២. ពាក្យ " អ្នកចុះកិច្ចសន្យា" សំដៅដល់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបពិតដែលធ្វើការផ្គត់ផ្គង់ដោយផ្ទាល់នូវផលិតផលឬសេវារបស់ខ្លួនចាប់ពី ៨០% ឡើងទៅ សម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង ។

៣. ពាក្យ " ធាតុចូលផលិតកម្ម" សំដៅដល់ទំនិញរួមបញ្ចូលទាំងវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងសម្ភារៈបន្ទាប់បន្សំសម្រាប់បម្រើផលិតកម្ម ដែលត្រូវបានបំប្លែងឬត្រូវបានប្រើប្រាស់យ៉ាងពេញលេញនៅក្នុងកិច្ចដំណើរការផលិតកម្មរបស់ឧស្សាកម្មគាំទ្រ ។

៤. ពាក្យ " សម្ភារៈបរិក្ខារផលិតកម្ម" សំដៅដល់គ្រឿងម៉ាស៊ីន ឧបករណ៍ ដែលបានប្រើប្រាស់ជាមូលដ្ឋានសំខាន់ក្នុងការបំប្លែងធាតុចូលផលិតកម្មរបស់ឧស្សាកម្មគាំទ្រ ។

៥. ឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យា ដូចមានចែងក្នុងកថាខ័ណ្ឌ១ និងកថាខ័ណ្ឌ២ ខាងលើនេះកម្រិតត្រឹមតែ :

- សហគ្រាសផលិតសំបកវេចខ្ចប់
- សហគ្រាសផលិតសរសៃអំបោះ ក្រណាត់ ឡេវ ខ្សែរូត ទំពក់ព្យួរ ដង្កៀបសម្លៀកបំពាក់ និងគ្រឿងភ្ជាប់នឹងសម្លៀកបំពាក់ ឬស្បែកជើង
- សហគ្រាសបោកគក់ ជ្រលក់ បោះពុម្ពលើក្រណាត់ ឬសម្លៀកបំពាក់ ដេរ ប៉ាក់ ។

**ប្រការ ២ .-**

១. អាករលើតម្លៃបន្ថែមអនុវត្តចំពោះឧស្សាហកម្មគាំទ្រ ត្រូវបានអនុគ្រោះដូចខាងក្រោម :

ក. អាករលើធាតុចូល :

- អាករលើតម្លៃបន្ថែមលើការនាំចូលនូវធាតុចូលផលិតកម្ម និងសម្ភារៈបរិក្ខារផលិតកម្មសម្រាប់ផលិតបំរើឱ្យការផ្គត់ផ្គង់ដោយផ្ទាល់ដល់ ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង ត្រូវបានចាត់ទុកជាបន្ទុករបស់រដ្ឋ ។ ក្នុងករណីមានបំណងលក់ធាតុចូលផលិតកម្មឬ/និងសម្ភារៈបរិក្ខារផលិតកម្ម ឧស្សាហកម្មគាំទ្រត្រូវជូនដំណឹងជាមុនដល់ទីចាត់ការគយ និងរដ្ឋាករ ។

  រាល់ការទិញទំនិញឬសេវាក្នុងស្រុកត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា១០ ភាគរយ ។

ខ. អាករលើធាតុចេញ :

- ការផ្គត់ផ្គង់ផលិតផល ឬសេវា សម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រាសូន្យភាគរយ
- ការផ្គត់ផ្គង់ផលិតផល ឬសេវា ទៅទីផ្សារក្នុងស្រុកត្រូវជាប់អាករលើតម្លៃបន្ថែម តាមអត្រា១០ ភាគរយ និងត្រូវបង់ពន្ធគយនិងអាករតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

២. អាករលើតម្លៃបន្ថែមអនុវត្តចំពោះអ្នកចុះកិច្ចសន្យា ត្រូវបានអនុគ្រោះដូចខាងក្រោម :

ក. អាករលើធាតុចូល :

- ការនាំចូល ឬការទិញក្នុងស្រុកនូវធាតុចូលផលិតកម្មនិងសម្ភារៈបរិក្ខារផលិតកម្ម ឬសេវានានាត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា ១០ ភាគរយ និងពន្ធអាករដទៃទៀតតាមច្បាប់ជាធរមាន ។ អ្នកចុះកិច្ចសន្យាអាចទទួលការផ្គត់ផ្គង់ដោយផ្ទាល់នូវធាតុចូលផលិតកម្មពីឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង ដែលជាភាគីនៃកិច្ចសន្យា ។

ខ. អាករលើធាតុចេញ :

- ការផ្គត់ផ្គង់ផលិតផល ឬសេវា សម្រាប់បម្រើឱ្យការនាំចេញរបស់ ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រាសូន្យភាគរយ
- ការផ្គត់ផ្គង់ផលិតផល ឬសេវា ទៅទីផ្សារក្នុងស្រុកត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា ១០ ភាគរយ ។ ក្នុងករណីដែលអ្នកចុះកិច្ចសន្យា ទទួលការផ្គត់ផ្គង់ធាតុចូលផលិតកម្មពីឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឬឧស្សាហកម្មផលិតស្បែកជើង មិនបានធ្វើការផ្គត់ផ្គង់គ្រប់ចំនួនតាមកិច្ចសន្យានិងបទដ្ឋានបច្ចេកទេសផលិតកម្ម អ្នកចុះកិច្ចសន្យាត្រូវបង់អាករលើតម្លៃបន្ថែមលើចំណែកដែលមិនបានផ្គត់ផ្គង់នោះ ហើយឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឬឧស្សាហកម្មផលិតស្បែកជើងត្រូវបង់ពន្ធគយនិងអាករលើធាតុចូលផលិតកម្មតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

៣. ការគណនាប្រាក់អាករលើតម្លៃបន្ថែមត្រូវបង់ ឥណទានអាករយោងទៅមុខ ឬស្នើសុំបង្វិលសងត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃជំពូកទី៦ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម លេខ១១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៩ ដែលបានធ្វើវិសោធនកម្មដោយអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ ។

**ប្រការ ៣ .-**

អ្នកចុះកិច្ចសន្យាត្រូវដាក់ពាក្យស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមទម្រង់ដែលបានកំណត់ដើម្បីទទួលបាននូវការអនុគ្រោះដូចមានចែងក្នុងកថាខណ្ឌ២ នៃប្រការ២ ខាងលើ សម្រាប់រយៈពេលមិនលើសពីមួយឆ្នាំក្នុងមួយលើកៗ ។

**ប្រការ ៤ ..**

១. ឧស្សាហកម្មគាំទ្រនិងអ្នកចុះកិច្ចសន្យា ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម :

ក. ឧស្សាហកម្មគាំទ្រ ត្រូវផ្តល់ជូនទីចាត់ការគយ និងរដ្ឋាករ នូវរបាយការណ៍ស្តីពីបរិមាណ សន្និធិ បញ្ចូល បញ្ចេញ នូវវត្ថុធាតុដើមនិងផលិតផល ជារៀងរាល់ខែតាមគំរូភ្ជាប់ជាមួយនឹងប្រកាសនេះ ។

ខ. ឧស្សាហកម្មគាំទ្រនិងអ្នកចុះកិច្ចសន្យា ត្រូវភ្ជាប់កិច្ចសន្យាស្តីពីការផ្គត់ផ្គង់ដល់ ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង ជាមួយនឹងលិខិតប្រកាសសារពើពន្ធដែលត្រូវដាក់ជូននាយកដ្ឋានពន្ធដារនៅខែបន្ទាប់ពីខែដែលបានចុះកិច្ចសន្យា ។

គ. រៀងរាល់ពេលផ្គត់ផ្គង់ផលិតផល ឬសេវា ឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យា ត្រូវចេញវិក្កយបត្រអាករឱ្យទៅឧស្សាហកម្មនាំចេញ ដោយគិតអាករលើតម្លៃបន្ថែមតាមអត្រាសូន្យភាគរយ ។

២. ក្នុងករណីមិនបានបំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងកថាខ័ណ្ឌ២ នៃប្រការ១ ឬ/និង មិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃប្រការនេះ ការអនុគ្រោះដូចមានចែងក្នុងប្រការ២ នឹងត្រូវដកហូត ។

៣. រាល់ពេលទទួលការផ្គត់ផ្គង់ ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង ត្រូវមានកាតព្វកិច្ចចេញលិខិតធានាអំពីការនាំចេញផលិតផលឬសេវា ឱ្យទៅឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យា ដូចមានគំរូភ្ជាប់មកជាមួយនឹងប្រកាសនេះ ។ ក្នុងករណីមិនបាននាំចេញនូវផលិតផល ឬសេវាដែលបានផ្គត់ផ្គង់ដោយឧស្សាហកម្មគាំទ្រឬអ្នកចុះកិច្ចសន្យា ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឬឧស្សាហកម្មផលិតស្បែកជើង ត្រូវទទួលខុសត្រូវបង់អាករលើតម្លៃបន្ថែម និងត្រូវបង់ពន្ធគយ និងអាកររួមទាំងទោសទណ្ឌទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**ប្រការ ៥ ..**

បទប្បញ្ញត្តិឬសេចក្តីសម្រេចនានាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦ ..**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយកទីចាត់ការគយនិងរដ្ឋាករ ប្រធាននាយកដ្ឋានពន្ធដារ និងប្រធានគ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៥

**គាត ឈន់**

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់ក្រសួង-ស្ថាប័ន
- សាលាខេត្ត-ក្រុង
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ